# បេឡាជាតិសន្តិសុខសង្គម

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែ

លេខ៖០១

ថ្ងៃចន្ទ ១០កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ត្រូវនឹង ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៥

## មាតិកា

### ព្រឹត្តិការណ៍សំខាន់ៗ


➤ ព្រឹត្តិការណ៍សំខាន់ៗ..........................................................២


### ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន


➤ ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស..............២០


### ការស្នើសុំតាវកាលិក (Online)


➤ របៀបប្រើប្រាស់ ការស្នើសុំតាវកាលិកពី ប.ស.ស. តាមកម្មវិធីទូរសព្ទដៃ ប.ស.ស. (NSSF Member App) ......................២៤


### អាសយដ្ឋាន ប.ស.ស.


➤ អាសយដ្ឋាន ប.ស.ស. ទាំងអស់ទីស្នាក់ការកណ្តាល ឬសាខាខេត្ត-ខណ្ឌ..........................................................២៦


ទាញយកប្រើប្រាស់ឥឡូវនេះ!!

NSSF Member App

Google Play

App Store




### រចនាសម្ព័ន្ធព្រឹត្តិបត្រ ខែមិថុនា ឆ្នាំ២០២៥

**ឯកឧត្តម ម៉េង ហុង**

**អគ្គនាយក ប.ស.ស.**

| | |
|---|---|
| **ចាងហ្វាង** | ឯកឧត្តមបណ្ឌិត **ហេង សុផាន់ណារិទ្ធ** |
| **និពន្ធនាយក** | លោក **អ៊ុក សំអូន** |
| **និពន្ធនាយករង** | លោកស្រី **ចាន់ ស៊ីណូន** |
| | លោក **យុន វិចិត្រ** |
| **លេខានិពន្ធ** | លោក **យន គន្ធា** |
| | លោក **អ៊ឹង លាងឆុង** |
| | លោក **យង់ សុខន** |
| **ផ្នែកភារីកុំព្យូទ័រ** | លោក **អ៊ុង ស៊ីខឿ** |
| | លោក **តូង គីមលាង** |
| | អ្នកស្រី **វ៉ិត បញ្ញា** |



សូមអានបន្តនៅទំព័រទី២



© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិសន្តិសុខសង្គម អាណត្តិទី២ បានបើកកិច្ចប្រជុំលើកទី២ របស់ខ្លួន




នារសៀលថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃបេឡាជាតិសន្តិសុខសង្គម បានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី២ លើកទី២ ដោយមានការអញ្ជើញចូលរួមពីសំណាក់ភាគីតំណាងរាជរដ្ឋាភិបាល ភាគីតំណាងនិយោជក ភាគីតំណាងសមាជិក ប.ស.ស. ដែលជាសមាជិកនៃក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. ចំនួន ០៨រូប និងប្រព្រឹត្តទៅដោយផ្ទាល់នៅទីស្នាក់ការកណ្ដាល ប.ស.ស. រាជធានីភ្នំពេញ។

កិច្ចប្រជុំនេះ ត្រូវបានធ្វើឡើងដោយផ្ដោតសំខាន់ទៅលើរបៀបវារៈចំនួន៣ រួមមាន៖ ទី(១). សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាវេជ្ជសាស្ត្រ នៃបេឡាជាតិសន្តិសុខសង្គម ទី(២). សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការកំណត់អត្រាភាគទានក្នុងរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារនិងផ្នែកថែទាំសុខភាពសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ និងទី(៣). ពិនិត្យលើបញ្ជីបេក្ខភាពសមាជិកឯករាជ្យ នៃក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គម នៃ ប.ស.ស.៕








© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម ម៉េង ហុង ប្រធានគណៈកម្មការទ្រទ្រង់មូលនិធិគន្ធបុប្ផាកម្ពុជា ប្រចាំបេឡាជាតិសន្តិសុខសង្គម អញ្ជើញចូលរួមពិធីបើកយុទ្ធនាការ "១ម៉ឺនរៀល ១ម៉ឺននាក់" ឆ្នាំ២០២៥




នាព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៥ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការទ្រទ្រង់មូលនិធិគន្ធបុប្ផាកម្ពុជា ប្រចាំបេឡាជាតិសន្តិសុខសង្គម ព្រមទាំងថ្នាក់ដឹកនាំ ប.ស.ស. បានអញ្ជើញចូលរួមពិធីបើកយុទ្ធនាការ «១ម៉ឺនរៀល ១ម៉ឺននាក់» ឆ្នាំ២០២៥ របស់មូលនិធិគន្ធបុប្ផាកម្ពុជា ដែលប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ប្រធានកិត្តិយសនៃមូលនិធិគន្ធបុប្ផាកម្ពុជា ស្ថិតក្នុងបរិវេណរូបសំណាក់ លោកយាយពេញ រមណីយដ្ឋានវត្តភ្នំ រាជធានីភ្នំពេញ។

ពិធីបើកយុទ្ធនាការ «១ម៉ឺនរៀល ១ម៉ឺននាក់» ជាគំនិតផ្តួចផ្តើមដ៏ថ្លៃថ្លារបស់**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដែលបានរៀបចំឡើង ២ឆ្នាំហើយ បើគិតទាំងឆ្នាំ២០២៥នេះ។ យុទ្ធនាការ «១ម៉ឺនរៀល ១ម៉ឺននាក់» បានឆ្លុះបញ្ចាំងពីចលនាជាតិក្នុង «ស្មារតីខ្មែរជួយខ្មែរ» បន្តបេសកកម្មរួមគ្នានាំក្តីសង្ឃឹម និងភាពញញឹមដល់ទារក និងកុមារកម្ពុជា ដែលចាប់ផ្តើមជាផ្លូវការចាប់ពីថ្ងៃទី១ និងបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥។

ដើម្បីចូលរួមក្នុងយុទ្ធនាការ «១ម៉ឺនរៀល ១ម៉ឺននាក់» ឆ្នាំ២០២៥នេះ **ឯកឧត្តម ម៉េង ហុង** ប្រធានគណៈកម្មការទ្រទ្រង់មូលនិធិគន្ធបុប្ផាកម្ពុជា ប្រចាំបេឡាជាតិសន្តិសុខសង្គម ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានចូលរួមចែករំលែកនូវក្តីស្រឡាញ់តាមរយៈការបរិច្ចាគថវិកាផ្ទាល់ខ្លួនជូនដល់មូលនិធិគន្ធបុប្ផាកម្ពុជា ដើម្បីសុខភាពទារក និងកុមារនៅកម្ពុជាផងដែរ៕








© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# កិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ ដើម្បីពិនិត្យ និងពិភាក្សាលើការអនុវត្តការងារ និងលើកផែនការការងារអាទិភាពរបស់នាយកដ្ឋានជំនាញ នៃ ប.ស.ស.



នាព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. ព្រមទាំងថ្នាក់ដឹកនាំ ប.ស.ស. បានចូលរួមកិច្ចប្រជុំផ្ទៃក្នុងកម្រិតថ្នាក់ដឹកនាំ ប.ស.ស. ក្រោមអធិបតីភាព **ឯកឧត្តម គួច សុមាន** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសាលប្រជុំមេត្តា ស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

កិច្ចប្រជុំនេះ រៀបចំឡើងដើម្បីពិនិត្យ និងពិភាក្សាលើការអនុវត្តការងារដើម្បីអនុលោមតាមបទប្បញ្ញត្តិ និងការងារអនុវត្តជាក់ស្តែង ព្រមទាំងពិនិត្យលើផែនការការងារអាទិភាពរបស់នាយកដ្ឋានជំនាញ ដើម្បីឆ្លើយតបបានទាន់ពេលវេលា ព្រមទាំងការងារចាំបាច់ចំពោះមុខ។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំនេះ មានការចូលរួមពីសំណាក់ ឯកឧត្តមអនុរដ្ឋលេខាធិការ និងថ្នាក់ដឹកនាំ ប.ស.ស. សរុបប្រមាណជា ៨០រូប។








© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# នាព្រឹកមិញនេះ ថ្នាក់ដឹកនាំ ប.ស.ស. បានបន្តកិច្ចប្រជុំពិភាក្សាលើការអនុវត្តការងារ និងលើកផែនការការងារអាទិភាពរបស់នាយកដ្ឋានជំនាញនីមួយៗ នៃ ប.ស.ស.



នាព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. ព្រមទាំងថ្នាក់ដឹកនាំ ប.ស.ស. បានបន្តចូលរួមកិច្ចប្រជុំពិភាក្សាលើការអនុវត្តការងារ និងលើកផែនការការងារអាទិភាពរបស់នាយកដ្ឋានជំនាញនីមួយៗ នៃ ប.ស.ស. ក្រោមអធិបតីភាព **ឯកឧត្តម គួច សុមាន** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសាលប្រជុំមេត្តា ស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

កិច្ចប្រជុំនេះ បានពិភាក្សាយ៉ាងផុសផុលទៅលើការអនុវត្តការងារប្រចាំថ្ងៃ ដើម្បីអនុលោមតាមបទប្បញ្ញត្តិ និងការងារអនុវត្តជាក់ស្តែងព្រមទាំងពិនិត្យលើផែនការការងារអាទិភាពរបស់នាយកដ្ឋានជំនាញនីមួយៗ ដើម្បីឆ្លើយតបឱ្យទាន់ពេលវេលាព្រមទាំងការងារចាំបាច់ចំពោះមុខ។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំនេះ មានការចូលរួមពីសំណាក់ ថ្នាក់ដឹកនាំ ប.ស.ស. សរុបប្រមាណជា ៧០រូប៕








© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# កិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង សម្រាប់បច្ចុប្បន្នភាពការងារ ចុះបញ្ជីមន្ត្រីសាធារណៈ និងមន្ត្រីចូលនិវត្តន៍ចូលមកក្នុង ប.ស.ស.



នាព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមការងារបច្ចេកទេសអន្តរក្រសួងសម្រាប់ចុះបញ្ជីមន្ត្រីសាធារណៈ ចូលមកក្នុង ប.ស.ស. បានដឹកនាំកិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីពិនិត្យលើបច្ចុប្បន្នភាពនីតិវិធីនៃការគ្រប់គ្រង និងការបញ្ជូនឈ្មោះមន្ត្រីសាធារណៈ និងមន្ត្រីចូលនិវត្តន៍ មក ប.ស.ស. ដើម្បីផ្តល់ប័ណ្ណសមាជិក ប.ស.ស. ឱ្យបានឆាប់រហ័ស ទាន់ពេលវេលា និងមានប្រសិទ្ធភាព។

កិច្ចប្រជុំពិភាក្សានេះ មានការចូលរួមពីក្រុមការងារបច្ចេកទេសអន្តរក្រសួង មកពីតំណាងក្រសួងមហាផ្ទៃ តំណាងក្រសួងមុខងារសាធារណៈ និងតំណាងមូលនិធិជាតិជំនួយសង្គម សរុបប្រមាណជា ២០នាក់ នៅសាលប្រជុំក្រុមប្រឹក្សាភិបាល ស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ៕



© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម ម៉េង ហុង ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. អញ្ជើញចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការ ធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធសំខាន់ៗរបស់រាជរដ្ឋាភិបាល




នាព្រឹកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារគណៈកម្មការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធសំខាន់ៗ រួមមាន៖ គ្រឹះស្ថានសិក្សាសាធារណៈ អង្គភាពសុខាភិបាលមូលដ្ឋាន និងក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី៧។

កិច្ចប្រជុំនាព្រឹកនេះ ប្រព្រឹត្តទៅក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តម ហ៊ុន ម៉ានី** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ មកពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ សរុបប្រមាណជា ១០០នាក់ នៅបន្ទប់ "តេជោសន្តិភាព" ជាន់ទី២ នៃអគារគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈក្នុងបរិវេណសាលាភូមិន្ទរដ្ឋបាល៕



© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ អញ្ជើញចូលរួមពិធីអបអរសាទរខួបលើកទី៧៦ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២៤ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៥




នាព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញចូលរួមពិធីអបអរសាទរខួបលើកទី៧៦ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២៤ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៥ ក្រោមប្រធានបទ "លើកកម្ពស់ការងារសមរម្យសម្រាប់កម្មករនិយោជិតវ័យក្មេងនៅគ្រប់ខ្សែច្រវ៉ាក់ផលិតកម្ម ដើម្បីធានាកំណើនប្រកបដោយចីរភាព និងភាពធន់" ក្រោមអធិបតីភាព**លោកជំទាវ សុវណ្ណ វណ្ណារតន៍** រដ្ឋលេខាធិការប្រចាំការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ។

ពិធីនេះ រៀបចំឡើងនៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានវត្តមានអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងថ្នាក់ដឹកនាំ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងតំណាងអង្គការជាតិ និងអន្តរជាតិប្រមាណជាង ៤០០នាក់ផងដែរ៕












© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# សិស្សនគរបាល នៃសាលានគរបាលជាតិភូមិភាគ៣ ខេត្តកំពង់ស្ពឺ ទទួលបានការផ្សព្វផ្សាយ អំពីការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព



នាព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥ សិស្សនគរបាល នៃវគ្គបណ្តុះបណ្តាលកម្រិតបឋមវិជ្ជាជីវៈនគរបាល ជំនាន់ទី១៩ នៃសាលានគរបាលជាតិភូមិភាគ៣ ខេត្តកំពង់ស្ពឺ ជាង ៣០០នាក់ ទទួលបានការផ្សព្វផ្សាយស្តីពីការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព ដែលពិធីនេះ ប្រព្រឹត្តទៅក្រោមសហធិបតីភាព **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង **លោកឧត្តមសេនីយ៍ទោ ហុង សុផា** នាយកសាលានគរបាលជាតិភូមិភាគ៣ នៃបណ្ឌិត្យសភានគរបាលកម្ពុជា។

ថ្លែងក្នុងពិធីផ្សព្វផ្សាយនេះ **ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានលើកឡើងថា ការផ្តល់ការថែទាំសុខភាពជូនដល់និស្សិតនគរបាល និងសិស្សនគរបាលនេះ គឺផ្តើមចេញពីការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់ប្រមុខរាជរដ្ឋាភិបាល ក្នុងការពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់និស្សិតនគរបាល និងសិស្សនគរបាល នៅពេលពួកគាត់ឈឺថ្កាត់ មាតុភាព ឬមានគ្រោះថ្នាក់ផ្សេងៗ ជាយថាហេតុ នោះនិស្សិតនគរបាល និងសិស្សនគរបាលអាចទទួលបានសេវាពិនិត្យ និងព្យាបាលដោយឥតគិតថ្លៃតាមរយៈ ប.ស.ស. ក្នុងអំឡុងពេលកំពុងសិក្សានេះផងដែរ។

**ឯកឧត្តមបណ្ឌិតអគ្គនាយករង ប.ស.ស.** បានបន្តទៀតថា ការផ្តល់ជូននេះ បច្ចុប្បន្នផ្តល់ជូនចំពោះតែសាមីខ្លួនដែលជាសិស្សនគរបាល និងនិស្សិតនគរបាលប៉ុណ្ណោះ ប៉ុន្តែនៅពេលដែលពួកគាត់ទាំងអស់បញ្ចប់ការសិក្សាដោយជោគជ័យ ហើយក្លាយជាមន្ត្រីនគរបាលពេញសិទ្ធិ រាជរដ្ឋាភិបាល ក៏មានគោលនយោបាយផ្តល់ជូនការគាំពារសុខភាពមួយនេះដល់ ប្តីឬប្រពន្ធ និងកូនៗ ក្នុងបន្ទុកផងដែរ ដែលរាល់បន្ទុកចំណាយបង់ភាគទានជាបន្ទុករបស់រាជរដ្ឋាភិបាលទាំងស្រុង។

ក្នុងឱកាសជាមួយគ្នានេះ **លោកឧត្តមសេនីយ៍ទោ ហុង សុផា** នាយកសាលានគរបាលជាតិភូមិភាគ៣ នៃបណ្ឌិត្យសភានគរបាលកម្ពុជា បានថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល និង ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពបានយ៉ាងសកម្ម និងរៀបចំបទបង្ហាញយ៉ាងលម្អិត និងមានសារៈសំខាន់នេះឡើង ដើម្បីឱ្យថ្នាក់ដឹកនាំ និងសិស្សនគរបាល នៃវគ្គបណ្តុះបណ្តាលកម្រិតបឋមវិជ្ជាជីវៈនគរបាល ជំនាន់ទី១៩ នៃបណ្ឌិត្យសភានគរបាលកម្ពុជា បានយល់ដឹងកាន់តែច្បាស់ពីអត្ថប្រយោជន៍របស់ខ្លួនដែលទទួលបានពី ប.ស.ស.៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ ដឹកនាំមន្ត្រីបច្ចេកទេស ប.ស.ស. ជួបពិភាក្សាការងារជាមួយក្រុមការងារមូលនិធិជាតិជំនួយសង្គម



នាព្រឹកថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. បានដឹកនាំមន្ត្រីបច្ចេកទេសនាយកដ្ឋានបញ្ជិកា និងភាគទាន នៃ ប.ស.ស. ជួបពិភាក្សាការងារជាមួយក្រុមការងារមូលនិធិជាតិជំនួយសង្គម លើនីតិវិធីផ្សេងៗ នៃការផ្តល់ប័ណ្ណសមាជិក ប.ស.ស. និង ប័ណ្ណមូលនិធិសមធម៌សុខាភិបាល នៅទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

ក្នុងកិច្ចប្រជុំនេះ **ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានអនុញ្ញាតឱ្យមន្ត្រីបច្ចេកទេស ជួបពិភាក្សាផ្លាស់ប្តូរយោបល់កម្រិតបច្ចេកទេស លើនីតិវិធីនៃការផ្តល់ប័ណ្ណសមាជិក ប.ស.ស. សម្រាប់អតីតយុទ្ធជន ដែលទើបនឹងផ្ទេរមកពីក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ដែលការងារនេះត្រូវធ្វើបច្ចុប្បន្នភាពចូលនិវត្តន៍ជាប្រចាំ ដើម្បីសម្របសម្រួលឱ្យពួកគាត់ទទួលបានប័ណ្ណសមាជិក ប.ស.ស. ទាន់ពេលវេលា និងត្រឹមត្រូវអាចប្រើប្រាស់សេវាបានប្រកបដោយប្រសិទ្ធភាព។

**ឯកឧត្តមបណ្ឌិតអគ្គនាយករង** ក៏បានលើកទឹកចិត្តដល់មន្ត្រីបច្ចេកទេសស្ថាប័នទាំងពីរត្រូវបន្តកិច្ចសហការរវាងគ្នា ប្រកបដោយភាពបុរេសកម្មដើម្បីឆ្លើយតបទាន់ពេលវេលាតាមតម្រូវការរបស់ជនគោលដៅ ដែលជួយលើកស្ទួយជីវភាពរស់នៅ និងកាត់បន្ថយទុក្ខលំបាកដល់និវត្តជន និងជនពិការជាអតីតយុទ្ធជន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលលើការផ្តល់ការថែទាំសុខភាពជូនអតីតយុទ្ធជនតាមរយៈប័ណ្ណសមាជិក ប.ស.ស. និងប័ណ្ណមូលនិធិសមធម៌សុខាភិបាល៕







© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម ប៉ែន នរៈវុធ អញ្ជើញចូលរួមពិធីបិទ ទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៨




នារសៀលថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥ **ឯកឧត្តម ប៉ែន នរៈវុធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញចូលរួមពិធីបិទទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៨ ឆ្នាំ២០២៥ ។

ពិធីបិទទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៨ ប្រព្រឹត្តទៅក្រោមអធិបតីភាព **លោកជំទាវ សុវណ្ណា វណ្ណារតន៍** រដ្ឋលេខាធិការប្រចាំការ តំណាង **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ៕













© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ប.ស.ស. បន្តផ្សព្វផ្សាយអំពីការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ជូនដល់សិស្សនគរបាលនៅសាលានគរបាលជាតិភូមិភាគ២ ខេត្តកំពង់ចាម



នាព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥ សិស្សនគរបាលនៅសាលានគរបាលជាតិភូមិភាគ២ ខេត្តកំពង់ចាម ជាង ៣០០នាក់ ទទួលបានការផ្សព្វផ្សាយស្តីពី ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ដែលពិធីនេះ ប្រព្រឹត្តទៅក្រោមសហធិបតីភាព **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង**លោកឧត្តមសេនីយ៍ទោ រ័ត្ន ចំរើន** នាយកសាលានគរបាលជាតិភូមិភាគ២។

ថ្លែងក្នុងពិធីផ្សព្វផ្សាយ **ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានលើកឡើងថា ការផ្តល់ការថែទាំសុខភាពជូនដល់និស្សិតនគរបាល និងសិស្សនគរបាលនេះ គឺទទួលបានការយកចិត្តទុកដាក់ខ្ពស់បំផុតពីប្រមុខរាជរដ្ឋាភិបាល ក្នុងការពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់និស្សិតនគរបាល និងសិស្សនគរបាល នៅពេលពួកគាត់មានបញ្ហាសុខភាព មាតុភាព ឬមានគ្រោះថ្នាក់ផ្សេងៗជាយថាហេតុ នោះនិស្សិតនគរបាល និងសិស្សនគរបាលអាចទទួលបានសេវាពិនិត្យ និងព្យាបាលដោយឥតគិតថ្លៃតាមរយៈ ប.ស.ស. ក្នុងអំឡុងពេលកំពុងសិក្សានេះផងដែរ។

**ឯកឧត្តមបណ្ឌិតអគ្គនាយករង** ប.ស.ស. បានបន្តទៀតថា ពិធីផ្សព្វផ្សាយនេះ ធ្វើឡើងដើម្បីឱ្យសិស្សនគរបាលនៅសាលានគរបាលជាតិភូមិភាគ២ ទាំងអស់បានឈ្វេងយល់កាន់តែច្បាស់អំពីវឌ្ឍនភាពថ្មីៗ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម ដែលនឹងក្លាយជាមូលដ្ឋានក្នុងការយកទៅអនុវត្ត និងផ្សព្វផ្សាយបន្តឱ្យកាន់តែទូលំទូលាយបន្ថែមទៀត។

ក្នុងឱកាសជាមួយគ្នា **លោកឧត្តមសេនីយ៍ទោ រ័ត្ន ចំរើន** នាយកសាលានគរបាលជាតិភូមិភាគ២ បានថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល និង ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពបានយ៉ាងសកម្ម និងរៀបចំបទបង្ហាញយ៉ាងលម្អិត និងមានសារៈសំខាន់នេះឡើង ដើម្បីឱ្យថ្នាក់ដឹកនាំ និងសិស្សនគរបាលនៅសាលានគរបាលជាតិភូមិភាគ២ បានយល់ដឹងកាន់តែច្បាស់ពីអត្ថប្រយោជន៍ និងសិទ្ធិ ដែលត្រូវទទួលបានពី ប.ស.ស.៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម យុន ចាន់ណារិទ្ធ អគ្គនាយករង ប.ស.ស. អញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាការងារជាមួយអង្គការអន្តរជាតិខាងការងារ ( ILO )



នារសៀលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥ **ឯកឧត្តម យុន ចាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ ប.ស.ស. ចូលរួមកិច្ចប្រជុំពិភាក្សាជាមួយតំណាងអង្គការអន្តរជាតិខាងការងារ (ILO) ក្នុងការគាំទ្រដល់ ប.ស.ស. ក្រោមគម្រោងកាតាលីករសកលស្តីពី ការងារសមរម្យ និងកិច្ចគាំពារសង្គមសម្រាប់អន្តរកាលយុត្តិធម៌ ដោយមានសមាសភាពចូលរួមសរុបចំនួន ១៤រូប ដែលបានប្រព្រឹត្តទៅនៅទីស្នាក់ការកណ្តាលនៃ ប.ស.ស.។

កិច្ចប្រជុំនេះមានគោលបំណងដើម្បីពិភាក្សាការងារ និងឈ្វេងយល់អំពីអត្ថប្រយោជន៍ និងវិសាលភាព នៃការអនុវត្តរបបសន្តិសុខសង្គម និងពិនិត្យលើការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ការត្រៀមដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ នៅពេលខាងមុខ។

ក្នុងឱកាសជាមួយគ្នា **ឯកឧត្តមអគ្គនាយករង** បានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ អង្គការអន្តរជាតិខាងការងារ (ILO) ដែលបានជួយគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដល់ ប.ស.ស. ដើម្បីជួយអភិវឌ្ឍស្ថាប័ន និងបង្កើនសមត្ថភាពមន្ត្រី និងបុគ្គលិកជំនាញនៃ ប.ស.ស. កន្លងមក។

សូមបញ្ជាក់ផងដែរថា គម្រោងកាតាលីករសកលនេះ ជាគំនិតផ្តួចផ្តើមដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិនៅឆ្នាំ២០២១ និងបានជ្រើសរើសប្រទេសកម្ពុជា ជាប្រទេសត្រួសត្រាយផ្លូវ សម្រាប់ដំណាក់កាលដំបូង៕





© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# តំណាងសហគ្រាស គ្រឹះស្ថាន និងសមាគមសហគ្រិនស្ត្រីកម្ពុជា ចូលរួមឈ្វេងយល់ "គោលការណ៍ បទប្បញ្ញត្តិ ច្បាប់ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម"



នាព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥ **ឯកឧត្តម គឹម កែវរស្មី** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជាអធិបតីបើកពិធីផ្សព្វផ្សាយស្តីពី "គោលការណ៍ បទប្បញ្ញត្តិ ច្បាប់ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម" ជូនដល់បណ្តាតំណាងម្ចាស់សហគ្រាស គ្រឹះស្ថាន និងសមាគមសហគ្រិនស្ត្រីកម្ពុជា(CWEA) សរុបប្រមាណ ១៥០នាក់ នៅសាលប្រជុំជាន់ទី៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មានប្រសាសន៍បើកពិធីផ្សព្វផ្សាយ **ឯកឧត្តមអគ្គនាយករង** ប.ស.ស. បានអំពាវនាវដល់ម្ចាស់អាជីវកម្មទាំងអស់ដែលមានកម្មករនិយោជិតចាប់ពីម្នាក់ឡើងទៅ ត្រូវមកចុះបញ្ជីជាមួយ ប.ស.ស. ឱ្យបានគ្រប់ៗគ្នា ជាពិសេសអ្នកក្នុងបន្ទុក ក៏អាចមកចុះបញ្ជីជាសមាជិក ប.ស.ស. នៅគ្រប់សាខា ប.ស.ស. ដែលនៅជិត ដើម្បីទទួលបានការព្យាបាលជំងឺនៅមន្ទីរពេទ្យដែលជាដៃគូ ប.ស.ស. ដោយឥតគិតថ្លៃ ព្រមទាំងទទួលបានអត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀត។

បន្ទាប់ពីពិធីផ្សព្វផ្សាយពេញមួយព្រឹកនេះ **ឯកឧត្តមអគ្គនាយករង** ប.ស.ស. សង្ឃឹមយ៉ាងមុតមាំថាម្ចាស់សហគ្រាស គ្រឹះស្ថាន និងសមាគមសហគ្រិនស្ត្រីកម្ពុជា ដែលបានចូលរួមនឹងអនុវត្តកាតព្វកិច្ចដែលមានចែងជាធរមាន នឹងបន្តផ្សព្វផ្សាយបន្ថែមទៀតគ្រប់រូបភាព ជាពិសេសសូមបង្កើនការទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធប្រសើរជាងមុនជាមួយនឹងក្រុមការងារ ប.ស.ស. ដើម្បីដោះស្រាយនូវរាល់បញ្ហាប្រឈមនានា ដែលប៉ះពាល់ដល់ប្រយោជន៍ស្ថាប័នខ្លួន ក៏ដូចជាអត្ថប្រយោជន៍របស់កម្មករនិយោជិតផងដែរ៕








© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# តំណាងសហគ្រាស គ្រឹះស្ថាន និងសមាគមសហគ្រិនស្ត្រីកម្ពុជា ចូលរួមឈ្វេងយល់ "គោលការណ៍ បទប្បញ្ញត្តិ ច្បាប់ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម"



ក្នុងឱកាសអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ការពង្រឹងសមត្ថភាពជនបង្គោលយេនឌ័រ" រយៈពេល ៣ថ្ងៃ ចាប់ពីថ្ងៃទី២៥-២៧ ខែមិថុនា ឆ្នាំ២០២៥ នៅរសៀលថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. បានអញ្ជើញចូលរួមធ្វើបទបង្ហាញស្តីពី បច្ចុប្បន្នភាព នៃការអនុវត្តរបបសន្តិសុខសង្គម ជូនដល់ជនបង្គោលយេនឌ័រក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សរុបប្រមាណជាង ២០០នាក់ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ក្នុងឱកាសធ្វើបទបង្ហាញនេះផងដែរ **ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានបង្ហាញអំពីវឌ្ឍនភាព នៃការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន ព្រមទាំងការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. ៕








© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# តំណាងសហគ្រាស គ្រឹះស្ថាន និងសមាគមសហគ្រិនស្ត្រីកម្ពុជា ចូលរួមឈ្វេងយល់ "គោលការណ៍ បទប្បញ្ញត្តិ ច្បាប់ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម"




នាព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥ ក្នុងឱកាសអញ្ជើញជាអធិបតីបើកពិធីផ្សព្វផ្សាយស្តីពី ការអនុវត្តរបបសន្តិសុខសង្គម ជូនសហព័ន្ធសហជីព **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានលើកឡើងថា តំណាងសហព័ន្ធសហជីពជាតួអង្គ និងជាដៃគូសហការដ៏សំខាន់ក្នុងសកម្មភាពចូលរួមផ្សព្វផ្សាយបន្ត អំពីអត្ថប្រយោជន៍របបសន្តិសុខសង្គម និងការពារសិទ្ធិ និងផលប្រយោជន៍របស់បងប្អូនកម្មករនិយោជិតពាក់ព័ន្ធនឹងវិស័យសន្តិសុខសង្គម។

**ឯកឧត្តមអគ្គនាយករង** បានមានប្រសាសន៍បន្ថែមទៀតថា ពិធីផ្សព្វផ្សាយនេះ គឺជាការពង្រឹងការយល់ដឹងបន្ថែមពាក់ព័ន្ធនឹងបច្ចុប្បន្នភាព និងវឌ្ឍនភាព នៃការអនុវត្តរបបសន្តិសុខសង្គម ដែលរាជរដ្ឋាភិបាល បានដាក់ចេញថ្មីៗ ដើម្បីឱ្យថ្នាក់ដឹកនាំ និងតំណាងសហព័ន្ធសហជីពទាំងអស់ ទទួលបានមូលដ្ឋានច្បាស់លាស់ ដែលអាចយកទៅផ្សព្វផ្សាយបន្តឱ្យបានគ្រប់ជ្រុងជ្រោយ និងសហការធ្វើសកម្មភាពរួមគ្នាឱ្យកាន់តែមានប្រសិទ្ធភាពសម្រាប់ជាប្រយោជន៍ដល់សមាជិក ប.ស.ស. ពិសេសបងប្អូនកម្មករនិយោជិត។

ក្នុងឱកាសជាមួយគ្នានេះដែរ **ឯកឧត្តមអគ្គនាយករង** បានសំណូមពរដល់ថ្នាក់ដឹកនាំសហព័ន្ធសហជីព និងបងប្អូនកម្មករនិយោជិត ប្រសិនបើបានទទួលព័ត៌មានអំពីភាពមិនប្រក្រតីណាមួយអំពីការមិនអនុវត្តកាតព្វកិច្ចរបស់និយោជក និងការប្រើប្រាស់សេវានៅតាមមូលដ្ឋានសុខាភិបាលដៃគូ ឬមានបញ្ហាប្រឈមពាក់ព័ន្ធនឹងសេវាសាធារណៈរបស់ ប.ស.ស. សូមរាយការណ៍មកកាន់លេខ Hotline: ១២៨៦/១២៩៧ ឬតាមរយៈប្រអប់បណ្តឹងអនាមិក ដើម្បី ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចាត់វិធានការ និងដោះស្រាយជូនបានទាន់ពេលវេលា។

សូមបញ្ជាក់ថា ពិធីផ្សព្វផ្សាយពេញមួយព្រឹកនេះ មានការធ្វើបទបង្ហាញពីមន្ត្រីជំនាញ ប.ស.ស. ជូនដល់ថ្នាក់ដឹកនាំ និងតំណាងសហព័ន្ធសហជីព ដែលចូលរួមប្រមាណជា ៣០០នាក់ ប្រព្រឹត្តទៅនៅសាលប្រជុំសន្តិភាព ទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ៕





© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# សិស្សនគរបាល នៃសាលានគរបាលជាតិភូមិភាគ៦ ក្នុងខេត្តកំពង់ឆ្នាំង ចូលរួមឈ្វេងយល់អំពីការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព



នៅរសៀលថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវបានអញ្ជើញជាអធិបតីបើកពិធីផ្សព្វផ្សាយ ស្តីពីការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ជូនដល់ថ្នាក់ដឹកនាំ និងសិស្សនគរបាល នៃសាលានគរបាលជាតិភូមិភាគ៦ សរុបប្រមាណជាង ៣០០នាក់។

ថ្លែងក្នុងពិធីផ្សព្វផ្សាយនេះ **ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានលើកឡើងថា ការផ្តល់ការថែទាំសុខភាពជូនដល់និស្សិតនគរបាល និងសិស្សនគរបាលនេះ គឺទទួលបានការយកចិត្តទុកដាក់ខ្ពស់បំផុតពីប្រមុខរាជរដ្ឋាភិបាល ក្នុងការពង្រីកវិសាលភាព នៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់និស្សិតនគរបាល និងសិស្សនគរបាល នៅពេលពួកគាត់មានបញ្ហាសុខភាព មាតុភាព ឬមានគ្រោះថ្នាក់ផ្សេងៗជាយថាហេតុ នោះនិស្សិតនគរបាល និងសិស្សនគរបាល អាចទទួលបានសេវាពិនិត្យ និងព្យាបាលដោយឥតគិតថ្លៃតាមរយៈ ប.ស.ស. ក្នុងអំឡុងពេលកំពុងសិក្សានេះផងដែរ។

**ឯកឧត្តមបណ្ឌិតអគ្គនាយករង** ប.ស.ស. បានបន្តទៀតថា ពិធីផ្សព្វផ្សាយនេះ ធ្វើឡើងដើម្បីឱ្យសិស្សនគរបាលនៅសាលានគរបាលជាតិភូមិភាគ៦ទាំងអស់ បានចូលរួមឈ្វេងយល់ឱ្យកាន់តែច្បាស់អំពីវឌ្ឍនភាពថ្មីៗ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម ដែលនឹងក្លាយជាមូលដ្ឋានក្នុងការយកទៅអនុវត្ត និងផ្សព្វផ្សាយបន្តឱ្យកាន់តែទូលំទូលាយបន្ថែមទៀត។

ក្នុងឱកាសជាមួយគ្នា **លោកឧត្តមសេនីយ៍ទោ តុង អាន** នាយកសាលានគរបាលជាតិភូមិភាគ៦ នៃបណ្ឌិត្យសភានគរបាលកម្ពុជា បានថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល និង ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពបានយ៉ាងសកម្ម និងរៀបចំបទបង្ហាញយ៉ាងលម្អិត និងមានសារៈសំខាន់នេះឡើង ដើម្បីឱ្យថ្នាក់ដឹកនាំ និងសិស្សនគរបាល នៃសាលានគរបាលជាតិភូមិភាគ៦ នៃបណ្ឌិត្យសភានគរបាលកម្ពុជា បានយល់ដឹងកាន់តែច្បាស់ពីអត្ថប្រយោជន៍របស់ខ្លួនដែលទទួលបានពី ប.ស.ស.៕







© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ថ្នាក់ដឹកនាំបេឡាជាតិសន្តិសុខសង្គម អញ្ជើញចូលរួមទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈលើកទី៨ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ




នាព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៥ ថ្នាក់ដឹកនាំបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញចូលរួមពិធីប្រកាសបើកជាផ្លូវការ ទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈលើកទី៨ ក្រោមប្រធានបទ«TVET បង្កើតឱកាសការងារ សាងក្តីសង្ឃឹមដល់យុវជន» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងឱកាសទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈលើកទី៨ បេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏មានស្តង់ពិព័រណ៍បង្ហាញអំពីសមិទ្ធផលការងារ និងចែករំលែកចំណេះដឹង ព័ត៌មានអំពីវិស័យសន្តិសុខសង្គមផងដែរ។ ជាមួយគ្នានេះ មហាជនក៏អាចចូលរួមសាកល្បងសមត្ថភាពឆ្លើយសំណួរពាក់ព័ន្ធនឹងការអនុវត្តរបបសន្តិសុខសង្គម ដើម្បីទទួលបានវត្ថុអនុស្សាវរីយ៍លើកទឹកចិត្តផងដែរ។

សូមបញ្ជាក់ថា៖ ទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈលើកទី៨ ប្រព្រឹត្តទៅរយៈពេល ២ថ្ងៃ ចាប់ពីថ្ងៃទី១៥ ខែមិថុនា រហូតដល់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ដែលសិស្ស និស្សិត និងសាធារណជនទូទៅអាចចូលរួមបានដោយសេរី ដើម្បីទស្សនា និងលើកទឹកចិត្តដល់ស្នាដៃសិស្ស និស្សិតដែលដាក់បង្ហាញក្នុងស្តង់ពិព័រណ៍ ព្រមទាំងពិព័រណ៍របស់ស្ថាប័នរដ្ឋ ស្ថាប័នឯកជន និងដៃគូអភិវឌ្ឍន៍នានាផងដែរ៕





© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# តំណាងសហគ្រាស គ្រឹះស្ថាន ប្រមាណជា ១៥០នាក់ បានចូលរួមឈ្វេងយល់ពី គោលការណ៍ បទប្បញ្ញត្តិច្បាប់ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម



ដោយទទួលបានការអនុញ្ញាតពីសំណាក់**ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាព្រឹកថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៥ **លោក ប៉ាង សុខជា** ប្រធានសាខា ប.ស.ស. ខេត្តសៀមរាប បានអញ្ជើញបើកពិធីផ្សព្វផ្សាយស្តីពី "គោលការណ៍ បទប្បញ្ញត្តិ ច្បាប់ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម" ជូនតំណាងសហគ្រាស គ្រឹះស្ថាន ប្រមាណជា ១៥០នាក់ ដែលប្រព្រឹត្តទៅនៅសាលប្រជុំធំ សាខា ប.ស.ស. ខេត្តសៀមរាប។

ពិធីផ្សព្វផ្សាយនាឱកាសនេះ រៀបចំឡើងក្នុងគោលបំណងដើម្បីពង្រឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម ឱ្យកាន់តែមានប្រសិទ្ធភាព និងមានវិសាលភាពគ្របដណ្តប់សមាជិកឱ្យកាន់តែទូលំទូលាយ និងបញ្ជ្រាបការយល់ដឹងឱ្យកាន់តែច្បាស់ អំពីកាតព្វកិច្ចដែលនិយោជកត្រូវអនុវត្ត ក្នុងការចុះបញ្ជីកម្មករនិយោជិត ការប្រកាសប្រាក់ឈ្នួលជាប់ភាគទាន រាយការណ៍អំពីចំនួនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម ព្រមទាំងអត្ថប្រយោជន៍នានាដែល ប.ស.ស. ផ្តល់ជូន នៅពេលបំពេញលក្ខខណ្ឌដែលបានកំណត់។

មានប្រសាសន៍បើកពិធីផ្សព្វផ្សាយខាងលើ លោកប្រធានសាខា ប.ស.ស. ខេត្តសៀមរាប បានជំរុញដល់តំណាងសហគ្រាស គ្រឹះស្ថាន និងក្រុមហ៊ុនទាំងអស់ ត្រូវធ្វើការឈ្វេងយល់អំពីគោលការណ៍ បទប្បញ្ញត្តិ ច្បាប់ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម ឱ្យច្បាស់ដើម្បីចៀសវាងការអនុវត្តខុស ដែលអាចប្រឈមនឹងច្បាប់ស្តីពីរបបសន្តិសុខសង្គម៕







© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស.






☛ប័ណ្ណ ប.ស.ស. ជួយខ្ញុំ និង គ្រួសារខ្ញុំ!



☛ប្អូនី ជាសមាជិក ប.ស.ស. ដែលបានរងគ្រោះថ្នាក់ការងាររហូតពិការ តែពិតជាសំណាង



☛Ep1 - Podcast ប.ស.ស. ប្រធានបទ៖ ប.ស.ស. ជាអ្វី?




☛កាន់តែស្រួល! ចង់ស្នើសុំតារកាលិកពី ប.ស.ស. មិនចាំបាច់មកដល់ ប.ស.ស. ទៀតទេ! ប្រើតែកម្មវិធីទូរសព្ទដៃ


© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស.




តើលោកអ្នកកំពុងចង់ដឹងពីសេវាព្យាបាលនៅតាមមន្ទីរពេទ្យថ្នាក់ជាតិ ដែលជាដៃគូ ប.ស.ស. ក្នុងរាជធានីភ្នំពេញមែនទេ? Posters ទាំងអស់នេះ អាចជួយលោកអ្នកបាន!

សម្រាប់ផ្តល់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកលេខ ១២៨៦ ឬ ១២៩៧!!

facebook

សូមស្កេន ដើម្បីមើលសេវាព្យាបាល នៅតាមមន្ទីរពេទ្យថ្នាក់ជាតិ ដែលជាដៃគូ ប.ស.ស. ក្នុងរាជធានីភ្នំពេញ




មែនហើយ! សមាជិក ប.ស.ស. ដែលមានសិទ្ធិទទួលបានប្រាក់សោធនជរាភាព (ប្រាក់ចូលនិវត្តន៍ ឬប្រាក់រ៉ឺត្រែត) គឺត្រូវបំពេញលក្ខខណ្ឌកំណត់មួយចំនួនដូចខាងក្រោម៖

✓ (១)- បានចុះបញ្ជីនៅ ប.ស.ស. ផ្នែកប្រាក់សោធន

✓ (២)- បានបង់ភាគទានមក ប.ស.ស. បានយ៉ាងតិច ១២ខែ

✓ (៣)- មានអាយុយ៉ាងតិច ៦០ឆ្នាំ

⚠ ចំណាំ៖ ដើម្បីអាចស្នើសុំប្រាក់សោធនជរាភាព (ប្រាក់ចូលនិវត្តន៍ ឬប្រាក់រ៉ឺត្រែត) សមាជិក ប.ស.ស. ត្រូវភ្ជាប់ឯកសារសំខាន់ៗដូចខាងក្រោម៖

✓ (១)- ប័ណ្ណសមាជិក ប.ស.ស. ច្បាប់ដើម

✓ (២)- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរច្បាប់ដើម (មានសុពលភាព) ឬលិខិតឆ្លងដែន (ជនបរទេស)

✓ (៣)- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងសេចក្តីសម្លងបញ្ជាក់សំបុត្រកំណើតកូន (បើមាន)

✓ (៤)- លេខគណនីធនាគារអេស៊ីលីដា (មិនមែនលេខអេស៊ីលីដាទាន់ចិត្ត) ឬលេខគណនីធនាគារ កាណាឌីយ៉ា

☎ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់លេខ ១២៨៦ ឬ១២៩៧ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គមរបស់យើង!!


© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស.

⚠ ជាការពិតណាស់ នៅពេលដែល ក្រុមហ៊ុន រោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីជាមួយ ប.ស.ស. រួចរាល់ និងមានប្រើប្រាស់បុគ្គលិកចាប់ពី ម្នាក់ឡើងទៅ ត្រូវមានកាតព្វកិច្ចផ្តល់ការធានារ៉ាប់រងដល់បុគ្គលិក ឬកម្មករនិយោជិតរបស់ខ្លួនតាមរយៈ ការចុះឈ្មោះចូលជាសមាជិក ប.ស.ស. និងបង់ភាគទានទៅលើរបបសន្តិសុខសង្គមដូចជា៖

✓ ផ្នែកហានិភ័យការងារ (បង់ភាគទានជាកាតព្វកិច្ចរបស់និយោជក)

✓ ផ្នែកថែទាំសុខភាព (បង់ភាគទានជាកាតព្វកិច្ចរបស់និយោជក)

✓ ផ្នែកប្រាក់សោធន (ការបង់ភាគទានផ្នែកប្រាក់សោធន គឺមានការចូលរួមពី និយោជក ៥០ភាគរយ និងសាមីខ្លួនជាសមាជិក ប.ស.ស. ៥០ភាគរយ)

✍ ចំណាំ៖ ក្នុងករណីលោកអ្នកសង្កេតឃើញថា ក្រុមហ៊ុនរបស់អ្នកប្រកាសប្រាក់ឈ្នួលមក ប.ស.ស. មិនត្រឹមត្រូវ កាត់ប្រាក់ឈ្នួលរបស់អ្នកសម្រាប់ការបង់ភាគទាន ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ឬមិនស្នើសុំប័ណ្ណ ប.ស.ស. សម្រាប់អ្នក សូមលោកអ្នករាយការណ៍មក ប.ស.ស. ភ្លាមៗ តាមរយៈ ប្រអប់បណ្តឹងអនាមិក (https://feedback.mlvt.gov.kh/feedback) ឬទាក់ទងមកលេខ ១២៨៦ ឬ ១២៩៧ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គមរបស់យើង!







កាន់តែងាយស្រួល! ឥឡូវនេះ សមាជិក ប.ស.ស. ទាំងអស់អាចពិនិត្យមើលថាប័ណ្ណ សមាជិក ប.ស.ស. របស់ខ្លួនមានសុពលភាព ប្រើប្រាស់សេវា ឬមិនមានសុពលភាពប្រើប្រាស់ សេវា ដោយគ្រាន់តែហៅមកកាន់លេខ ១២៨៦ នោះលោកអ្នកក៏អាចដឹងពីសុពលភាពប័ណ្ណ សមាជិក ប.ស.ស. របស់អ្នកបាន ដោយគ្រាន់តែ ធ្វើតាមការណែនាំ ដូចមានភ្ជាប់ក្នុង Poster ខាងលើ

☎ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង មកកាន់លេខ ១២៨៦ ឬ ១២៩៧ ឬតាមរយៈ ប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គមរបស់យើង!

# ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស.

✍ ចំណាំ៖ ក្នុងករណីលោកអ្នកសង្កេតឃើញថា ក្រុមហ៊ុនរបស់អ្នកប្រកាសប្រាក់ឈ្នួលមក ប.ស.ស. មិនត្រឹមត្រូវ កាត់ប្រាក់ឈ្នួលរបស់អ្នកសម្រាប់ការបង់ភាគទានផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ឬមិនបង់ភាគទានផ្នែកប្រាក់សោធន ឬមិនស្នើសុំប័ណ្ណ ប.ស.ស. សម្រាប់អ្នក សូមលោកអ្នករាយការណ៍មក ប.ស.ស. ភ្លាមៗ តាមរយៈ

✅ ប្រអប់បណ្ដឹងអនាមិក (https://feedback.mlvt.gov.kh/feedback)

✅ ប្រអប់សារ Facebook page ផ្លូវការរបស់ ប.ស.ស. (https://www.facebook.com/nssfpage)

✅ ឬទាក់ទងមកលេខ ១២៨៦ ឬ ១២៩៧

⚠ បញ្ជាក់៖ រាល់ម្ចាស់ក្រុមហ៊ុន រោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលមិនអនុវត្តកាតព្វកិច្ចបង់ភាគទានជូននិយោជិតរបស់ខ្លួន នឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ស្តីពីរបបសន្តិសុខសង្គមជាធរមាន។







✨ងាយៗ! នៅពេលលោកអ្នកបាត់ ឬខូចប័ណ្ណសមាជិក ប.ស.ស. សូមលោកអ្នកជូនដំណឹងមកកាន់ស្នាក់ការ ឬសាខា ប.ស.ស. ណាមួយដែលនៅជិតបំផុត ដើម្បីស្នើសុំបោះពុម្ពប័ណ្ណថ្មីប្រើប្រាស់ឡើងវិញ។

សម្រាប់ការស្នើសុំបោះពុម្ពប័ណ្ណថ្មីនេះ តម្រូវឱ្យភ្ជាប់មកនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរច្បាប់ដើម មកកាន់ស្នាក់ការ ឬសាខា ប.ស.ស. ណាមួយដែលនៅជិតលោកអ្នកបាន។

បញ្ជាក់៖ ការស្នើសុំបោះពុម្ពប័ណ្ណ ឬទុតិយតាឡើងវិញត្រូវចំណាយប្រាក់ ៥ ០០០រៀល។

☎ សម្រាប់ផ្តល់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកលេខ ១២៨៦ ឬ ១២៩៧!!




ឥឡូវនេះ! អ្នកដែលកំពុងបម្រើការងារក្នុងផ្ទះទាំងអស់ ក៏អាចស្នើសុំចុះឈ្មោះចូលជាសមាជិក ប.ស.ស. និងមានសិទ្ធិទទួលបានការគាំពារពី ប.ស.ស. ទាំងផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធន។

ដើម្បីស្នើសុំចូលជាសមាជិក ប.ស.ស. ម្ចាស់ផ្ទះត្រូវមកស្នើសុំចុះបញ្ជីជាមួយ ប.ស.ស. ដែលនៅជិតបំផុត បន្ទាប់មកត្រូវបញ្ជូនអ្នកបម្រើការងារក្នុងផ្ទះរបស់អ្នក មកស្នើសុំធ្វើប័ណ្ណសមាជិក ប.ស.ស. ដើម្បីមានសិទ្ធិក្នុងការប្រើប្រាស់សេវា ប.ស.ស. ជាមួយនឹងការទទួលបានអត្ថប្រយោជន៍របបសន្តិសុខសង្គមជាច្រើនទៀត។

✍ចំណាំ៖ សម្រាប់ការស្នើសុំធ្វើប័ណ្ណសមាជិក ប.ស.ស. ក៏អាចស្នើសុំតាមរយៈកម្មវិធីទូរសព្ទដៃ ប.ស.ស. (NSSF Member App) បានដែរ ដោយលោកអ្នកមិនចាំបាច់មកទីស្នាក់ការ ប.ស.ស. ដោយផ្ទាល់នោះទេ ។

☎ សម្រាប់ផ្តល់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកលេខ ១២៨៦ ឬ ១២៩៧!!


© រក្សាសិទ្ធិដោយបេឡាជាតិរបបសន្តិសុខសង្គម

# តើលោកអ្នកបានស្នើសុំតាវកាលិកពី ប.ស.ស. ដោយមិនចាំបាច់មកដល់ទីស្នាក់ប.ស.ស. ហើយឬនៅ?




កាន់តែស្រួល! លោកអ្នកអាចស្នើសុំតាវកាលិកពី ប.ស.ស. មិនចាំបាច់មកដល់ ប.ស.ស. ទៀតទេ បានដោយខ្លួនឯង ដោយត្រឹមរយៈពេលតែប៉ុន្មាននាទីប៉ុណ្ណោះ ដោយប្រើតែកម្មវិធីទូរសព្ទដៃ ប.ស.ស. (NSSF Member App) របស់បេឡាជាតិសន្តិសុខសង្គម។ **ងាយស្រួល ចំណេញពេលវេលា និង ថវិកា**!

# របៀបប្រើប្រាស់ ការស្នើសុំតាវកាលិកពី ប.ស.ស. តាមកម្មវិធីទូរសព្ទដៃ ប.ស.ស. (NSSF Member App)






















YouTube

សូមស្កេន ដើម្បីទស្សនាវីដេអូណែនាំអំពី
ការស្នើសុំតាវកាលិកពី ប.ស.ស.
តាមកម្មវិធីទូរសព្ទដៃ ប.ស.ស.
NSSF Member App

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# របៀបប្រើប្រាស់ ការស្នើសុំតារកាលិកពី ប.ស.ស. តាមកម្មវិធីទូរសព្ទដៃ ប.ស.ស. (NSSF Member App) (ត)























© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម



# បេឡាជាតិសន្តិសុខសង្គម

## សូមស្វាគមន៍

សូមទូរសព្ទទៅកាន់ **១២៨៦** ឬ **១២៩៧** រួចចុច លេខតំណភ្ជាប់របស់អង្គភាព

(ដោយមិនចាំបាច់ជ្រើសរើសភាសា)

ដើម្បីទាក់ទងទៅកាន់ទីស្នាក់ការ ប.ស.ស. ឬសាខាខេត្ត-ខណ្ឌ

**ដោយឥតគិតថ្លៃ**

# អាសយដ្ឋាន ប.ស.ស. ទីស្នាក់ការកណ្ដាល និងសាខាខេត្ត-ខណ្ឌ

បេឡាជាតិសន្តិសុខសង្គម — www.nssf.gov.kh

០២៣ ៨៨២ ៤៣៤ / ០២៣ ៨៨១ ០១៥ / ០២៣ ៨៨២ ៦២៣

ផ្លូវបេតុង ភូមិបន្លាស្អិត សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទីស្នាក់ការកណ្ដាល ប.ស.ស.

### ស្នាក់ការកណ្ដាល ប.ស.ស.
ផ្លូវបេតុង ភូមិសំរោង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ ភ្នំពេញ
លេខទំនាក់ទំនង ០២៣ ៨៨២ ៤៣៤ ។ ០២៣ ៨៨១ ០១៥ ។ ០២៣ ៨៨២ ៦២៣

### សាខា ប.ស.ស. ក្រុងកំពង់ឆ្នាំង
ភូមិទី០៤ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
លេខទំនាក់ទំនង ០៧៧ ៦៣ ២១៦ ។ ០៨១ ៩៩១ ៩១១ ។ ០២៣ ៩៨៨ ៤០៤

### សាខា ប.ស.ស. ខេត្តសៀមរាប
ផ្ទះលេខ១៣-១៥ ផ្លូវបណ្ដោយទី១ ភូមិខ្វារ សង្កាត់ជ្រាវ ក្រុងសៀមរាប
លេខទំនាក់ទំនង ០១២ ៥៣៤ ៣៤៥ ។ ០៩៨ ៦៦៥ ៤៣២ ។ ០៦៣ ៩៦៥ ៩៣៥

### សាខា ប.ស.ស. ខេត្តកោះកុង
ផ្ទះលេខ២៦ ភូមិ៣ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
លេខទំនាក់ទំនង ០៩៧ ៩៧៣ ៩០០៦ ។ ០១២ ៦២៥ ៨៥៥ ។ ០១៥ ៦២៩ ៩៤៤

### សាខា ប.ស.ស. ខណ្ឌឫស្សីកែវ
ផ្ទះលេខ269-70 ផ្លូវA&B ភូមិផ្សារលិច សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ
លេខទំនាក់ទំនង ០៧៨ ៨៨០ ០១៨ ។ ០៩៨ ៦២៥ ៩០៤ ។ ០២៣ ៩៨៨ ៣៤០

### សាខា ប.ស.ស. ស្រុកកំពង់ត្រឡាច
ភូមិតាកុល ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង
លេខទំនាក់ទំនង ០១២ ៩០៧ ២០១ ។ ០៩៣ ៩៤៧ ២៩៩ ។ ០២៣ ៩៨៨ ៤០៤

### សាខា ប.ស.ស. ខេត្តកំពង់ធំ
ភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
លេខទំនាក់ទំនង ០៩៧ ៣៣៥ ៦៣៣ ។ ០១៦ ៧៤៧ ០៩៩ ។ ០៩២ ៧៤៧ ០៩៩

### សាខា ប.ស.ស. ខេត្តស្ទឹងត្រែង
ភូមិថ្មលាត សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
លេខទំនាក់ទំនង ០១២ ៤០៥ ៤៥១ ។ ០២៣ ៩៨៨ ៣៥៩

### សាខា ប.ស.ស. ខណ្ឌពោធិ៍សែនជ័យ
ផ្ទះលេខJ140-142 ផ្លូវផ្កាចំប៉ា ភូមិតានួន សង្កាត់កំបូល ខណ្ឌកំបូល
លេខទំនាក់ទំនង ០៧៧ ៧១៦ ៧១៧ ។ ០២៣ ៩៨៨ ៣៤២

### សាខា ប.ស.ស. ក្រុងកំពង់ចាម
ភូមិបឹងកុក២ សង្កាត់បឹងកុក ក្រុងកំពង់ចាម ខេត្តកំពង់ចាម
លេខទំនាក់ទំនង ០៧៧ ៩៩០ ០៤៨ ។ ០៩៦ ៩៩៤ ៣៩៨៧ ។ ០៧០ ៦៧៨ ៩១៩

### សាខា ប.ស.ស. ខេត្តពោធិ៍សាត់
ភូមិស្ពានថ្ម សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់
លេខទំនាក់ទំនង ០១១ ៩៨៩ ០៤៨ ។ ០៩២ ៧០៧ ៣៨៥ ។ ០៥២ ៩៥១ ១២៣

### សាខា ប.ស.ស. ខេត្តក្រចេះ
ភូមិអូរឫស្សី១ សង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ
លេខទំនាក់ទំនង ០៩២ ៨៧៣ ០៥១ ។ ០៩៧ ២៦២ ៧៥៤៧ ។ ០២៣ ៩៨៨ ៣៥៧

### សាខា ប.ស.ស. ខណ្ឌមានជ័យ
ផ្ទះលេខ៤៤៦ ផ្លូវជាតិលេខ១ ភូមិតាព្រហ្ម សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ
លេខទំនាក់ទំនង ០១៥ ៩៧៧ ៧៦៧ ។ ០២៣ ៩៨៨ ៣៤១

### សាខា ប.ស.ស. ស្រុកជើងព្រៃ
ភូមិរវៀង ឃុំខ្នុរដំបង ស្រុកជើងព្រៃ ខេត្តកំពង់ចាម
លេខទំនាក់ទំនង ០១០ ៧៥២ ៣៣៦ ។ ០៨៦ ៥៦២ ៩០០ ។ ០២៣ ៩៨៨ ៤១៣

### សាខា ប.ស.ស. ខេត្តបាត់ដំបង
ផ្ទះលេខ១១៧ ភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
លេខទំនាក់ទំនង ០៩៧ ៩៩៧ ២៧២៩ ។ ០៧៧ ៧៧៦ ៨៤៥ ។ ០៩៨ ៥៤៨ ៧៣៤

### សាខា ប.ស.ស. ខេត្តមណ្ឌលគិរី
ភូមិចំការតែ សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី
លេខទំនាក់ទំនង ០១២ ២០៥ ៧៥៦ ។ ០៨៨ ៨២០ ៥៧៥៦ ។ ០២៣ ៩៨៨ ៣៥៨

### សាខា ប.ស.ស. ខណ្ឌដង្កោ
ផ្ទះលេខA01-02 ផ្លូវរដ្ឋ16m ភូមិគោកបន្ទាយ សង្កាត់ព្រៃស ខណ្ឌដង្កោ (បុរី មរកត)
លេខទំនាក់ទំនង (០៩៨/០៨៩) ៥០០ ៥៣៤ ០១៥ ៨៥២ ៤២៤ / ០៩៨ ៥៦៧ ៦៧៧

### សាខា ប.ស.ស. ក្រុងស្វាយរៀង
ផ្លូវជាតិលេខ១ បុរីសែនមង្គល ផ្ទះលេខ១១-១២ ភូមិស្វាគ សង្កាត់ចេក
លេខទំនាក់ទំនង ០១២ ៧៦៨ ៦៥៨ ។ ០៨៦ ៣៨២ ៩១១៤ ។ ០៩៧ ៥៥៥ ៥០២១

### សាខា ប.ស.ស. ខេត្តត្បូងឃ្មុំ
ផ្លូវថ្នល់ជាតិ ភូមិជ្រៃបិទមាស សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ
លេខទំនាក់ទំនង ០៩៦ ២៨៨ ៦៦៦៦ ។ ០១២ ៧៦៣ ៨៣៤ ។ ០២៣ ៩៨៨ ៤០៥

### សាខា ប.ស.ស. ខេត្តរតនគិរី
ផ្ទះលេខក3.021(ស្ទួន) ភូមិទេសអន្លង់ សង្កាត់បឹងកន្សែង ក្រុងបានលុង
លេខទំនាក់ទំនង ០១១ ៤៥១ ៧៧៧ ។ ០៩៧ ៩៦៦ ៧៦៦៦ ។ ០៧៥ ៩៧៤ ១៩៤

### សាខា ប.ស.ស. ក្រុងតាខ្មៅ
ភូមិដើមមៀន១ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល
លេខទំនាក់ទំនង ០៩៧ ៨៨៨ ៦៧៣៣ ។ ០៩៨ ៣៩២ ២២៧ ។ ០២៣ ៩៨៨ ៤១១

### សាខា ប.ស.ស. ក្រុងបាវិត
ភូមិជ្រៃធំ សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង
លេខទំនាក់ទំនង ០១២ ៧៦៨ ៦៥៨ ។ ០៨៦ ៣៨២ ៩១១៤ ។ ០៩៧ ៥៥៥ ៥០២១

### សាខា ប.ស.ស. ខេត្តព្រះវិហារ
ផ្លូវថ្លុកព្រៃ ភូមិកណ្ដាល សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ
លេខទំនាក់ទំនង ០៩៧ ៣៦៦ ៦០៦០ ។ ០១២ ២៥៩ ២៥៨ ។ ០៩៩ ៥៦៩ ២៥៦

### សាខា ប.ស.ស. ខេត្តកែប
ភូមិអូរក្រសារ សង្កាត់អូរក្រសារ ក្រុងកែប ខេត្តកែប
លេខទំនាក់ទំនង ០១២ ៩៩៣ ៨៧៧ ។ ០៧០ ៤៧៨ ០៧៧ ។ ០៨៨ ៣០៧ ០២៧០

### សាខា ប.ស.ស. ស្រុកខ្សាច់កណ្ដាល
ភូមិអន្លង់ ផ្លូវលេខ០៨ ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល
លេខទំនាក់ទំនង ០១២ ៧៨៨ ៧១១ ។ ០៦៩ ៧៨៨ ៧១១ ។ ០២៣ ៩៩៩ ២១៩

### សាខា ប.ស.ស. ក្រុងសិរីសោភ័ណ
ផ្ទះលេខD៤២ បុរីយ៉េម ណារី ភូមិ១ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ
លេខទំនាក់ទំនង ០៨៩ ៩៨៧ ៨៨៧ ។ ០២៣ ៩៨៨ ៤១៨

### សាខា ប.ស.ស. ខេត្តព្រៃវែង
ភូមិបារាយណ៍លិច សង្កាត់បារាយណ៍ ក្រុងព្រៃវែង ខេត្តព្រៃវែង
លេខទំនាក់ទំនង ០១២ ៣៦៣ ៩៨៦ ។ ០៩២ ៧០៨ ៨០៣ ។ ០៩៦ ៣៦៥ ៣០៨៦

### សាខា ប.ស.ស. ខេត្តព្រះសីហនុ
ភូមិ១ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
លេខទំនាក់ទំនង ០៧៧ ៦៦៣ ២១៥ ។ ០១៥ ៥១៦ ០០៨ ។ ០១៦ ៥៦៥ ៩៥៨

### សាខា ប.ស.ស. ខេត្តកំពង់ស្ពឺ
ភូមិព្រៃផ្ដៅ ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
លេខទំនាក់ទំនង ០១២ ៥៤១ ១៩៨ ។ ០៨៦ ៥៤១ ១៩៨ ។ ០២៣ ៩៨៨ ៤១២

### សាខា ប.ស.ស. ក្រុងប៉ោយប៉ែត
ភូមិផ្សារកណ្ដាល សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត
លេខទំនាក់ទំនង ០១១ ៤៤៤ ៤៥១ ។ ០២៣ ៩៨៨ ៤១៨

### សាខា ប.ស.ស. ខេត្តប៉ៃលិន
ភូមិបរឌិននៀវ សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន
លេខទំនាក់ទំនង ០៨៦ ៨៩៣ ៧៧៧ ។ ០១៥ ៨៨៨ ៨៤០ ។ ០៥៥ ៩៥៦ ៦៦៧

### សាខា ប.ស.ស. ខេត្តកំពត
ភូមិបឹងតារោង សង្កាត់ព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត
លេខទំនាក់ទំនង ០១២ ៦២៣ ៣៣២ ។ ០១៧ ២៥៦ ០៦២ ។ ០៣៣ ៩៣២ ១៣៣

### សាខា ប.ស.ស. ក្រុងដូនកែវ
ភូមិស្មោរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ
លេខទំនាក់ទំនង ០១២ ៣៤៣ ៣៤៦ ។ ០១៦ ២៦៦ ៨៩៩ ។ ០៧៨ ៤៥៥ ៧៦៤

### សាខា ប.ស.ស. ស្រុកបាទី (ត្រាំខ្នារ)
ភូមិច្បារមន ឃុំគុមារាជា ស្រុកបាទី ខេត្តតាកែវ
លេខទំនាក់ទំនង ០៩៨ ៨៨៤ ២៨៨ ។ ០៩៦ ៣៣៨ ៧០៤៣ ។ ០៧០ ៨០៨ ៣៥៤

### សាខា ប.ស.ស. ខេត្តឧត្ដរមានជ័យ
ភូមិឈូក សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្ដរមានជ័យ
លេខទំនាក់ទំនង ០៩៧ ៥២៣ ៤៦៦៦ ។ ០៩៥ ៣១១ ៣០០ ។ ០២៣ ៩៨៨ ៣៥៦

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

បណ្ដាញសង្គម ប.ស.ស. Telegram Facebook Youtube Tiktok Website Linkedin

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**


**ក្រសួងព័ត៌មាន**

**អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍**
General Department of Information and Broadcasting


លេខ : ០៤៤ ព.ស-អ.ព

ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២៥

## លិខិតអនុញ្ញាត

**យោង ៖** -ប្រកាសលេខ ១០៨ ប្រក.ព.ម ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ក្រសួងព័ត៌មាន
-លិខិតលេខ ៤១០/២២ .ធត.ប្រ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ របស់រដ្ឋបាលរាជធានីភ្នំពេញ
-លិខិតស្នើសុំប្តូរឈ្មោះ និងទីតាំង ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៥ របស់បេឡាជាតិសន្តិសុខសង្គម។

តាមសេចក្តីដូចមានចែងក្នុងយោងខាងលើ អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន សូមជម្រាបជូន ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម ជ្រាបថា អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន អនុញ្ញាតឱ្យព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម** ប្តូរឈ្មោះមកជាព្រឹត្តិបត្រ **បេឡាជាតិសន្តិសុខសង្គម** ដែលសរសេរជាអក្សរកាត់ថា ប.ស.ស. និងមានអាសយដ្ឋានទីស្នាក់ការថ្មីស្ថិតនៅផ្លូវបេតុង ភូមិសំរោង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ បន្តលិខិតលេខ ៤១០/២២-ធត.ប្រ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ របស់រដ្ឋបាលរាជធានីភ្នំពេញ។

ក្នុងដំណើរការផ្សព្វផ្សាយ ត្រូវគោរពអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារប្រកាស របស់ក្រសួងព័ត៌មាន ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន។ ករណីប្រព្រឹត្តល្មើស សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

លិខិតអនុញ្ញាតនេះមានសុពលភាពរយៈពេល ០១ (មួយ)ឆ្នាំ គិតពីថ្ងៃចុះហត្ថលេខាតទៅ។

ព្រឹត្តិបត្រ **បេឡាជាតិសន្តិសុខសង្គម** ត្រូវស្នើសុំបន្តសុពលភាពដើម្បីធ្វើសកម្មភាពការងារលើវិស័យព័ត៌មាន និងសោតទស្សន៍ មុនផុតកំណត់រយៈពេល ៣០ (សាមសិប) ថ្ងៃ។

**អគ្គនាយក**

**ផុស_សុវណ្ណ**

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន
- អគ្គស្នងការនគរបាលជាតិ
- និយ័តករទូរគមនាគមន៍កម្ពុជា
- រដ្ឋបាលរាជធានីភ្នំពេញ
- មន្ទីរព័ត៌មានរាជធានីភ្នំពេញ
  " ដើម្បីជូនជ្រាប "
- ឯកសារ កាលប្បវត្តិ